FIRST FINANCE

A HOME WITHIN REACH

# របាយការណ៍ ប្រចាំឆ្នាំ ២០១១



## យើងត្រៀមជាស្រេចសំរាប់ កំណើនអាជីវកម្ម តំណាក់កាលបន្ទាប់

អាគារ A-15-17 ផ្លូវលេខ 271 សង្កាត់ ទំនប់ទឹក
ខណ្ឌ ចំការមន ភ្នំពេញ រាជាណាចក្រកម្ពុជា
T: +855 (0) 023 997 937 | F: +855 (0) 23 997 937
E: info@firstfinance.biz | W: www.firstfinance.biz
www.facebook.com/firstfinance

# មាតិកា


៤- សាររបស់ប្រធានក្រុមប្រឹក្សាភិបាល
៥- សាររបស់អគ្គនាយក
៦- សាររបស់ទីប្រឹក្សាជាន់ខ្ពស់
៨- សាររបស់វិនិយោគិន
១០- សមិទ្ធផលសំខាន់ៗផ្នែកហិរញ្ញវត្ថុ
១២- សមិទ្ធផលសំខាន់ៗផ្នែកប្រតិបត្តិការ
១៤- សារតារបស់វិនិយោគិន/ ភាគទុនិក
១៦- ប្រវត្តិក្រុមហ៊ុន ហ្វឹស ហ្វាយនែន ភីអិលស៊ី
២៤- ការចូលរួមចំណែកក្នុងសង្គម
២៦- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
២៩- របាយការណ៍របស់សវនករឯករាជ្យ
៣០- របាយការណ៍ហិរញ្ញវត្ថុ



# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្រុមហ៊ុន ហ្វឹស ហ្វាននែន ភីអិលស៊ី ត្រូវបានបង្កើតឡើងដើម្បីពង្រីក និងធ្វើឲ្យប្រសើរឡើងនូវភាពជាម្ចាស់ផ្ទះសម្បែង សំរាប់ប្រជាជនខ្មែរដែលរស់នៅតាមតំបន់ប្រជុំជនដែលមានការលូតលាស់ជាលំដាប់ ។ នៅក្នុងឆ្នាំប្រតិបត្តិការទី៣ យើងបានបន្តរៀនសូត្រ និងធ្វើឲ្យមានភាពប្រសើរ ចំពោះការងារសង្គមជាស្នូលនេះ ដោយរក្សានូវផលប័ត្រឥណទានដែលមានទ្រព្យបញ្ចាំពេញលេញ និងស្ថេរភាពហិរញ្ញវត្ថុ ។

ក្នុងនាមជាក្រុមហ៊ុនមួយដែលទើបចាប់ផ្តើមដំបូង ការស្វែងរកប្រភពទុនក្រៅពីភាគទុនិករបស់ក្រុមហ៊ុនគឺជាការលំបាក ។ ប្រតិបត្តិការក្នុងវិស័យថ្មីជាអ្នកឯកទេសផ្តល់ឥណទានផ្ទះសម្បែងខ្នាតតូច សំរាប់ផ្ទះដែលមានតម្លៃទាប បានបន្ថែមទំងន់ទៅលើទស្សនៈហានិភ័យ (ស្ថិតក្នុងស្ថានភាពវិបត្តិសេដ្ឋកិច្ចពិភពលោក ស្ថាប័នផ្តល់ឥណទានផ្ទះសម្បែងមិនត្រូវបានចាត់ទុកថាជាអ្នកផ្តល់ដំណោះស្រាយទេ ផ្ទុយទៅវិញត្រូវបានគេចាត់ទុកថាជាអ្នកប្រព្រឹត្តខុស ។) ទោះបីជាយ៉ាងណាក៏ដោយ ធនាគារពាណិជ្ជ គឺជាអ្នកផ្តល់ឥណទានដល់ ក្រុមហ៊ុន ហ្វឹស ហ្វាយនែន មុនគេ ។ ក្នុងឆ្នាំ២០១១ ដោយស្ថានភាពមានការប្រែប្រួល វិយោគិនសង្គម និងអ្នកផ្តល់កម្ចីបានចាប់អារម្មណ៍នឹងទស្សនៈវិស័យ និងផែនការកំណើនអាជីវកម្មរបស់ក្រុមហ៊ុន ។ Oikocredit គឺជាអ្នកផ្តល់កំម្ចីមីក្រូហិរញ្ញវត្ថុទី១ដែលបានចាប់ផ្តើមធ្វើការជាមួយ ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ។ លើសពីនេះទៀត យើងក៏បានចុះកិច្ចសន្យាឥណទានដែលអាចផ្លាស់ប្តូរជាដើមទុន ជាមួយក្រុមហ៊ុន Emerging Market Investments (EMI) ផងដែរ។ ឆ្នាំ២០១១ គឺជាឆ្នាំដែលក្រុមហ៊ុន ហ្វឹស ហ្វាយនែន ត្រូវទាក់ទាញរកប្រភពទុនថ្មីដែលមានលក្ខខណ្ឌល្អប្រសើរ ។

ទីផ្សារអចលនទ្រព្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ផ្តើមមាន សកម្មភាពឡើងវិញក្នុងឆ្នាំ ២០១១នេះ ដោយមានអ្នកផ្តល់កម្ចីជាច្រើនបានចូលមកទីផ្សារហិរញ្ញវត្ថុផ្ទះសម្បែងសំរាប់អ្នកទិញដែលមានកំរិតចំណូលខ្ពស់ និងមធ្យម ។ យើងព្យាករណ៍ថានឹងមានការប្រកួតប្រជែងដែលយើងពុំធ្លាប់ជួបពីមុនមក ហើយយើងនឹងធ្វើការពិនិត្យឡើងវិញនូវទំរង់អាជីវកម្មរបស់យើងក្នុងឆ្នាំ២០១២ ដើម្បីធានាថាផលិតផលរបស់យើង នៅតែបន្តមានទីផ្សារ ហើយនិងពង្រឹងនូវអត្តសញ្ញាណរបស់យើង ។

បញ្ហាប្រឈមដ៏ចម្បងមួយផ្សេងទៀតគឺ កង្វះខាតនៃផ្ទះដែលមានតំលៃក្រោម ១៥,០០០ដុល្លារអាមេរិក។ក្រុមហ៊ុនហ្វឹសហ្វាននែននៅតែបន្តសហការជាមួយដៃគូរអភិវឌ្ឍន៍ផ្ទះសម្បែងផ្សេងៗ ដូចជា Urban Village ដើម្បីជំរុញឲ្យមានការវិនិយោគនៅលើផ្ទះសម្បែងដែលមានតំលៃថោកសមរម្យ ។ ទោះបីជាមានភាពប្រឈមយ៉ាងនេះក៏ដោយ ក៏យើងនៅតែឃើញមានការរីកចំរើនផ្នែកការងារសង្គមរបស់ក្រុមហ៊ុន ដោយទំហំប្រាក់កម្ចីជាមធ្យម តម្លៃផ្ទះជាមធ្យម និងចំណូលគ្រួសារនៃអតិថិជនថ្មី មានទំហំតូចទាបជាងមុន ។

ឆ្នាំ២០១២គឺជាឆ្នាំដែលផ្តោតជាសំខាន់លើកំណើនអាជីវកម្ម ពីព្រោះប្រភពទុនថ្មីបានអនុញ្ញាតឲ្យយើងពង្រីកវិសាលភាព ប្រតិបត្តិការក្នុងក្រុងភ្នំពេញ និងទីប្រជុំជននៅតាមបណ្តាខេត្តផ្សេងៗទៀត ។ ដើម្បីគាំទ្រដល់កំណើននេះ យើងក៏បានផ្តោតការយកចិត្តទុកដាក់លើ អភិបាលកិច្ចល្អជាមួយនឹងបុគ្គលិកដែលមានសមត្ថភាព រចនាសម្ព័ន្ធគណកម្មការថ្មី និងប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង។

ក្រុមប្រឹក្សាភិបាល សូមថ្លែងអំណរគុណដល់លោក លឹម ហាក់ឃុន និងបុគ្គលិកទាំងអស់ ។ ការបង្កើតអាជីវកម្មគឺជារឿងមួយដែលពិបាក ស្មុគស្មាញ និងពោរពេញទៅដោយហានិភ័យ ។ យើងបានធ្វើដំណើរមកដល់ផ្លូវបត់មួយ ដោយយើងបានបញ្ជាក់នូវអ្វី ដែលអាចមានដំណើរការបានទាំងផ្នែកការងារសង្គម និងផ្នែកហិរញ្ញវត្ថុ ហើយយើងអាចមានលទ្ធភាពរកបានប្រភពទុនថ្មីទៀតសំរាប់ការអភិវឌ្ឍន៍នាពេលខាងមុខ ។ យើងសង្ឃឹមថានឹងអាចជួយឲ្យគ្រួសារខ្មែរដែលមានចំណូលទាប និងមធ្យម ក្លាយជាម្ចាស់ផ្ទះលើកដំបូងកាន់តែច្រើនឡើង ។

**TALMAGE MARK PAYNE**
ប្រធានក្រុមប្រឹក្សាភិបាល



# សាររបស់អគ្គនាយក



## យើងមានមោទនភាពចំពោះសមិទ្ធផល ដែលយើងទទួលបាន ហើយនិងបានត្រៀមខ្លួនជាស្រេច សំរាប់កំណើនអាជីវកម្មតំណាក់កាលបន្ទាប់

ឆ្នាំ២០១១ គឺជាឆ្នាំដែលក្រុមហ៊ុនបានបោះមូលដ្ឋានអាជីវកម្មយ៉ាងរឹងមាំសំរាប់កំណើនអាជីវកម្មដែលប្រកបដោយគុណភាព និងស្ថេរភាពនាឆ្នាំ២០១២ និងឆ្នាំខាងមុខ ។ ក្រុមហ៊ុន ហ្វឹស ហ្វាយនែន បានជំនះនូវរាល់បញ្ហាប្រឈមអាជីវកម្មដោយជោគជ័យ ក្នុងដំណាក់កាលនីមួយៗនៃដំណើរអាជីវកម្មរបស់ខ្លួន ហើយមានការវិវឌ្ឍន៍ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ដោយចាប់ផ្តើមពីការទទួលបាន អាជ្ញាប័ណ្ណប្រតិបត្តិការលើកដំបូងនៅឆ្នាំ ២០០៩ ហើយនិងមានមូលដ្ឋានអាជីវកម្មយ៉ាងរឹងមាំ ប្រាក់ចំណេញក៏បានកើនឡើងនៅក្នុងឆ្នាំ ២០១១ ។

ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន មានភាពរលូនទៅបានដោយសារតែមានការទុកចិត្ត និងការគ្រាំទ្រកាន់តែច្រើនឡើងពីសំណាក់អតិថិជន សហគមន៍អាជីវកម្មក្នុងស្រុក សហគមន៍វិនិយោគិនថ្នាក់ជាតិនិងតំបន់ និយតករឧស្សាហកម្ម បុគ្គលិកដែលមានសមត្ថភាព និងការអនុវត្តន៍នូវអាជីវកម្មដែលប្រកបដោយក្រមសីលធម៌ខ្ពស់ ។ សមិទ្ធផលអាជីវកម្មទាំងអស់នេះត្រូវបានឆ្លុះបញ្ចាំង តាមរយៈកំណើនផលប័ត្រឥណទាននិងទ្រព្យសកម្ម ការពង្រីកតំបន់ប្រតិបត្តិការ និងការវិនិយោគបន្ថែមដោយវិនិយោគិនថ្នាក់តំបន់មួយចំនួន រួមមាន Oikocredit ធនាគារ Hwang DBS និង CLDF ។

នៅឆ្នាំ ២០១១នេះ ក្រុមហ៊ុនមានវិវឌ្ឍនាការគួរឲ្យកត់សំគាល់ក្នុងការសម្រេចគោលដៅហិរញ្ញវត្ថុនិងការងារសង្គមរបស់ខ្លួន ។ បើធៀបនឹងឆ្នាំ ២០១០ ប្រាក់ចំណេញបានកើនឡើង ១០០% ឯចំណាយប្រតិបត្តិការបានធ្លាក់ចុះ ។ ទុនរបស់ភាគទុនិកបានកើនឡើងចំនួន ១.៩៨៩.៣៧០ ដុល្លារអាមេរិក តាមរយៈបំលាស់ប្តូរនៃឥណទានរបស់ POEM Pte. Ltd , Insitor Funds, និង First Home Plc ។

ជាមួយនឹងការពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួន និងតាមរយៈការផ្តល់សេវាហិរញ្ញប្បទានផ្ទះសម្បែង ក្រុមហ៊ុន ហ្វឹស ហ្វាយនែន បានចូលរួមធ្វើការផ្លាស់ប្តូរជាវិជ្ជមាន ដល់ជីវភាពរបស់ប្រជាពលរដ្ឋខ្មែរជាង១ពាន់នាក់ ដែលមានចំណូលថវិកាទាប សាវតាសង្គម និងស្ថានភាពរស់នៅផ្សេងៗគ្នា និងដែលបានធ្លាប់ស្រមៃចង់រស់នៅក្នុងផ្ទះដែលជាកម្មសិទ្ធរបស់ខ្លួន ។

តាងនាមឲ្យគណៈគ្រប់គ្រង់ នៃក្រុមហ៊ុន ហ្វឹស ហ្វាននែន ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីថ្លែងអំណរគុណដល់ភាគទុននិក ក្រុមប្រឹក្សាភិបាល បុគ្គលិក អតិថិជន និយតករ និងដៃគូអាជីវកម្មទាំងអស់ដែលបាន និងកំពុងបន្តគាំទ្រ ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ជារៀងរហូតមក ។ ជាមួយនឹងការគាំទ្រនេះ ខ្ញុំមានសុទិដ្ឋិនិយមថា ក្រុមហ៊ុន ហ្វឹស ហ្វាយនែន នឹងបន្តរីកលូតលាស់ផ្នែកហិរញ្ញវត្ថុ ការងារសង្គម និងតំបន់ប្រតិបត្តិការនាឆ្នាំខាងមុខនេះ ទោះបីជាមានការប្រឈមយ៉ាងណាដ៏ដោយ ។

**លឹម ហាក់ឃុន (ខេវិន)**
អគ្គនាយក




# សាររបស់ទីប្រឹក្សាជាន់ខ្ពស់

ខ្ញុំមានការរំភើបជាពន់ពេកដែលត្រូវបាន ក្រុមហ៊ុន ហ្វឹស ហ្វាយនែន អញ្ជើញឲ្យត្រឡប់មកវិញនៅអំឡុង ខែ១១ ឆ្នាំ២០១១ ដល់ ខែ២ ឆ្នាំ២០១២ ហើយនិងចង់ដឹងថាតើក្រុមហ៊ុនមានដំណើរការយ៉ាងណា ។

ក្រុមហ៊ុន ហ្វឹស ហ្វាយនែន មានដំណើរការល្អ សកម្មភាពអាជីវកម្មមានការកើនឡើង បុគ្គលិកត្រូវបានពង្រឹង និងតួនាទីសំខាន់ៗមួយចំនួនត្រូវបានបំពេញ ។ បុគ្គលិកបានទទួលការបណ្តុះបណ្តាលបន្ថែម ។ ប៉ុន្តែព្រឹត្តិការណ៍ដែលសំខាន់បំផុតសំរាប់ខ្ញុំ គឺការបើកដំណើរការសាខាសៀមរាបនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១២ ។ ខ្ញុំត្រូវបានអញ្ជើញដោយលោក លីម ហាក់ឃុន អគ្គនាយកនៃក្រុមហ៊ុន ហ្វឹស ហ្វាយនែន ឲ្យបានជាគ្នាជាមួយគាត់ និងលោក ហេង សក្កា ដើម្បីទៅរកមើលទីតាំងដើម្បីបើកសាខានៅសៀមរាប ។ យើងបានប្រទះឃើញទីតាំងជាច្រើន ហើយទីបំផុតយើងបានជ្រើសរើសយកទីតាំងទល់មុខផ្សារលើ ដែលជាទីតាំងមួយងាយនឹងរកឃើញជាទីបំផុត។ នៅថ្ងៃបើកដំណើរការសាខានោះយើងបានទទួលការដាក់ពាក្យស្នើរសុំឥណទាន ដែលនេះពិតជាលទ្ធផលល្អមួយ ខ្ញុំបានយល់អំពីការសាទរ និងការរំភើបរបស់បុគ្គលិកក្នុងការធ្វើយុទ្ធនាការណ៍ផ្សព្វផ្សាយតាមដងផ្លូវ ។ យើងបានប្រារព្ធពិធីជប់លៀងមួយនៅល្ងាចនោះដែលជាព្រឹត្តិការណ៍នៃការរួមកំលាំងការងារជាក្រុមដ៏មានប្រសិទ្ធិភាពបំផុតដែលខ្ញុំធ្លាប់បានចូលរួម ។

បុគ្គលិកគឺជាទ្រព្យដ៏ប្រសើរបំផុតរបស់ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ។ ពួកគេនៅក្មេង មានថាមពល និងមានការប្តេជ្ញាចិត្តយ៉ាងមុតមាំ ។ ពួកគាត់មានកំរិតវិជ្ជាជីវៈខ្ពស់ ហើយយើងមានសំណាងណាស់ដែលបានពួកគេមកធ្វើការជាមួយ ។

ក្នុងអំឡុងពេលដែលខ្ញុំបានធ្វើការនៅ ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ខ្ញុំមានឲ្យកាសជួប និងពិភាក្សាអំពីគោលដៅរបស់ក្រុមហ៊ុន ជាមួយភាគទុនិកនិងអ្នកផ្តល់កម្ចី ។ ខ្ញុំបានចូលរួមក្នុងកិច្ចប្រជុំអំពីការបង្កើតផលិតផលថ្មី និងការពិភាក្សាអំពីគំរោងថវិកា និងទស្សនៈវិស័យរបស់ក្រុមហ៊ុន។ ខ្ញុំក៏បានចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលផងដែរ។ ជារួមខ្ញុំមាន ទស្សនៈវិជ្ជមានចំពោះភាពខ្លាំង និងគោលដៅរបស់ភាគីពាក់ព័ន្ធនឹងក្រុមហ៊ុន ។ ខ្ញុំមានក្តីរីករាយចំពោះសាមគ្គីភាព ការតាំងចិត្ត និងការតស៊ូយ៉ាងរឹងមាំដែលជាមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍របស់ក្រុមហ៊ុន ។

ខ្ញុំសូមថ្លែងអំណរគុណ ដល់អ្នកទាំងអស់ដែលខ្ញុំបានធ្វើការជាមួយ ជាពិសេសមិត្តរបស់ខ្ញុំ លោកអគ្គនាយក លីម ហាក់ឃុន ដែលជាអ្នកបានធ្វើឲ្យគ្រប់ផ្នែកមានដំណើរការល្អ និងលោកស្រី ជួន សុថានី ជានាយកផ្នែកហិរញ្ញវត្ថុដែលមានទេពកោសល្យ ផ្នែកហិរញ្ញវត្ថុដ៏គួរឲ្យកោតសរសើរ ហើយនិងប្រធានផ្នែកឥណទានគឺ លោក ហេង សក្កា ដែលជាអ្នកបង្កើតឲ្យមានសាទរភាព និងការប្តេជ្ញាចិត្តខ្ពស់ក្នុងក្រុមមន្ត្រីឥណទានដែលបានចូលរួមវិភាគទានក្នុងការធ្វើឲ្យក្រុមហ៊ុន ហ្វឹស ហ្វាយនែន ជាទីកន្លែងធ្វើការមួយដ៏ល្អ ។ ការអភិវឌ្ឍន៍ជាច្រើននឹងកើតមានចំពោះក្រុមហ៊ុន ហ្វឹស ហ្វាយនែន ហើយខ្ញុំសង្ឃឹមថានឹងអាចមានឱកាសចូលរួមម្តងទៀតក្នុងឆ្នាំ ២០១២-២០១៣ ។

**STEPHEN B. PIECE**
ទីប្រឹក្សាជាន់ខ្ពស់

# យើងមានមោទនភាពចំពោះសមិទ្ធផលដែលយើងទទួលបាន ហើយនិងបានត្រៀមខ្លួនជាស្រេចសំរាប់កំណើនអាជីវកម្មតំណាក់កាលបន្ទាប់ៗ



# សាររបស់វិនិយោគិន




## សាររបស់ លោក JOSHUA,MORRIS នាយកគ្រប់គ្រង នៃ ក្រុមហ៊ុន EMERGING MARKETS INVESTMENTS

នៅក្នុងឆ្នាំ ២០១១ Cambodia-Laos Development Fund (CLDF) បានផ្តល់ឲ្យក្រុមហ៊ុន ហ្វឹស ហ្វាយនែន នូវកម្ចីរយៈពេលវែងដែលអាចផ្លាស់ប្តូរជាដើមទុនបាន ដែលនឹងត្រូវយកប្រើប្រាស់ដើម្បីបង្កើនផលប័ត្រឥណទានរបស់ក្រុមហ៊ុន ពង្រីកតំបន់ប្រតិបត្តិការសំខាន់ៗ និងពង្រឹងប្រតិបត្តិការរបស់ខ្លួនតាមរយៈការវិនិយោគលើ ប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងរចនាសម្ព័ន្ធនៃការគ្រប់គ្រង ។

CLDF ដែលគ្រប់គ្រងដោយ Emerging Markets Investments (EMI) ផ្តោតជាសំខាន់លើការវិនិយោគ ទៅលើសហគ្រាសធុនតូច និងមធ្យម ដែលមានការគ្រប់គ្រងប្រកបដោយតម្លាភាព ភាពច្នៃប្រឌិត និងជំនាញការណ៍ច្បាស់លាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រទេសឡាវ ។ ជាមួយនឹងមូលនិធិបានមកពី វិទ្យាស្ថានអភិវឌ្ឍន៍ហិរញ្ញវត្ថុ នៃប្រទេស ហ្វាំងឡង់ ហូឡង់ ណ័រវេ៉ និង ស្វីស (Development Finance Institutions of Finland, and Netherlands, Norway and Switzerland) ក៏ដូចជាសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) CLDF ស្វែងរកនូវចំណូលហិរញ្ញវត្ថុសមស្របជូនវិនិយោគិនរបស់ខ្លួន ស្របពេលជាមួយគ្នា រួមចំណែកជួយឲ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចក្នុងប្រទេសទាំងពីរ ។

ការវិនិយោគរបស់យើងនៅក្នុងក្រុមហ៊ុន ហ្វឹស ហ្វាយនែន គឺត្រូវគ្នាឥតខ្ចោះជាមួយនឹងលក្ខខ័ណ្ឌវិនិយោគ និងគោលដៅនៃមូលនិធិ ក្នុងការឧបត្ថម្ភគាំទ្រលើអាជីវកម្មប្រកបដោយតម្លាភាព ដែលជួយអោយមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច នៃប្រទេសកម្ពុជា ។ ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ក្នុងការគាំទ្រ និងការយល់ដឹងច្បាស់អំពីតម្រូវការហិរញ្ញវត្ថុរបស់គ្រួសារដែលមានចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងគណៈគ្រប់គ្រងដែលពោរពេញដោយសមត្ថភាព គោលនយោបាយឥណទានប្រកបដោយការប្រុងប្រយ័ត្ន ហើយនិងការបង្កើតផលិតផលថ្មីសំរាប់ទីផ្សាររបស់ខ្លួន បានធ្វើឲ្យក្រុមហ៊ុន ហ្វឹស ហ្វាយនែន ជាក្រុមហ៊ុនល្អវិសេស សំរាប់ផលប័ត្រវិនិយោគរបស់យើង ។

យើងទន្ទឹងរង់ចាំក្នុងការធ្វើការជាមួយនឹងគណៈគ្រប់គ្រង ភាគទុនិក របស់ក្រុមហ៊ុន ដើម្បីឲ្យក្រុមហ៊ុន ហ្វឹស ហ្វាយនែន រីកលូតលាស់ ក្លាយទៅជាក្រុមហ៊ុនឯកទេសហិរញ្ញវត្ថុឈានមុខគេ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

Joshua Morris,
នាយកចាត់ការ, EMI

## សាររបស់លោក កុក កៅ ប្រធានប្រចាំប្រទេស OIKOCREDIT CAMBODIA

Oikocredit គឺជាស្ថាប័នអភិវឌ្ឍន៍ហិរញ្ញវត្ថុអន្តរជាតិដែលផ្តល់ឥណទាន និងមូលធនវិនិយោគដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Cooperatives and Fair Trade Organizations និងសហគ្រាសសង្គមផ្សេងៗ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ បច្ចុប្បន្ន Oikocredit គឺជាស្ថាប័នមួយក្នុងចំណោមស្ថាប័នដែលផ្តល់មូលធនឯកជន ដល់វិស័យមីក្រូហិរញ្ញវត្ថុធំជាងគេបំផុតលើពិភពលោក។ នៅចុងឆ្នាំ ២០១១ Oikocredit បានមានវត្តមាននៅស្ទើរតែ ៧០ ប្រទេស ហើយមានស្ថាប័នជាដៃគូប្រមាណ ៩០០ ស្ថាប័ន។ ស្ថាប័នជាដៃគូរបស់ Oikocredit នៅក្នុងប្រទេសកម្ពុជាមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១១ និងសហគ្រាសសង្គមចំនួន ៣។

បេសកកម្មរបស់ Oikocredit គឺដើម្បីលើកកម្ពស់យុត្តិធម៌សកល ដោយធ្វើការគាងគរប្រជាពលរដ្ឋ churches និងស្ថាប័នឬក្រុមផ្សេងៗទៀត ក្នុងការចែករំលែកធនធានរបស់ពួកគាត់តាមរយៈវិនិយោគសង្គម ដោយអនុញ្ញាតិឲ្យប្រជាពលរដ្ឋក្រីក្រទទួលបានប្រាក់កម្ចី។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានផ្តល់នូវកម្ចីជូនប្រជាពលរដ្ឋក្រីក្រ ដែលមិនមានលទ្ធភាពទទួលកម្ចីពីធនាគារពាណិជ្ជ ឬពីប្រភពហិរញ្ញប្បទានផ្សេងៗ ។ Fair Trade Organizations និងសហគ្រាសសង្គម មានតួនាទីបង្កើត របរចិញ្ចឹមជីវិតជូនប្រជាជន និងឱកាសសេដ្ឋកិច្ច នៅក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួន។

យោងតាមការស្វែងយល់ដោយមានការយកចិត្តទុកដាក់ខ្ពស់ ( Due Diligence ) អំពីស្ថានភាពហិរញ្ញវត្ថុ និងសមិទ្ធផលការងារសង្គមរបស់ក្រុមហ៊ុន ហ្វឹស ហ្វាយនែន Oikocredit បានសម្រេចសហការជាមួយក្រុមហ៊ុន ហ្វឹស ហ្វាយនែនតាមរយៈការផ្តល់មូលធនកម្ចី ។ ភាពជាដៃគូនេះ គឺផ្អែកជាសំខាន់ទៅលើទិសដៅការងារសង្គមរបស់ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ក្នុងការជួយដល់គ្រួសារដែលមានចំណូលទាប និងមធ្យមឲ្យទទួលបាននូវភាពជាម្ចាស់ផ្ទះដំបូងក្នុងក្តីស្រមៃរបស់ពួកគាត់ តាមរយៈសេវាកម្មហិរញ្ញប្បទានផ្ទះសំម្បែង។

លោក កុក កៅ
ប្រធានប្រចាំប្រទេសកម្ពុជា Oikocredit Cambodia

# សមិទ្ធផលផ្នែកហិរញ្ញវត្ថុ

## ផលប័ត្រឥណទាន

| | |
|---|---|
| 2011 | $ 3,333,189 |
| 2010 | $ 2,049,039 |
| 2009 | $ 491,282 |

## ប្រាក់ចំណេញសុទ្ធ

| | |
|---|---|
| 2011 | $ 116,150 |
| 2010 | $ 57,362 |
| 2009 | ($ 43,009) |

## ចំណូលទទួលបានពីមូលនិធិភាគទុនិក

| | |
|---|---|
| 2011 | 8.50% |
| 2010 | 20.08% |
| 2009 | (-16.74%) |

## ចំណូលទទួលបានពីទ្រព្យសកម្ម

| | |
|---|---|
| 2011 | 3.80% |
| 2010 | 3.72% |
| 2009 | (5.60%) |

## អនុបាតថ្លៃដើមប្រតិបត្តិការ

| | |
|---|---|
| 2011 | 11.24% |
| 2010 | 15.94% |
| 2009 | 16.42% |

## ទ្រព្យសកម្ម

| | |
|---|---|
| 2011 | 3,797,023 |
| 2010 | 2,319,510 |
| 2009 | 767,690 |

## មូលនិធិភាគទុនិក

| | |
|---|---|
| 2011 | 2,419,873 |
| 2010 | 314,353 |
| 2009 | 256,991 |

# សមិទ្ធផលផ្នែកប្រតិបត្តិការ

## គោលការណ៍ឥណទាន ១០ ចំណុច

10

តាំងពីពេលចាប់ផ្តើមដំបូងមក ក្រុមហ៊ុន ហ្វីស ហ្វាយនែន បាននិងកំពុងអនុវត្តគោលការណ៍ឥណទាន ១០ ចំណុចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ និងតម្លាភាព ដែលគោលការណ៍នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលដើម្បីធានាឲ្យមានកិច្ចការពារអតិថិជនក្នុងដំណើរការវាយតម្លៃឥណទាន:

1. វាយតម្លៃអត្តចរិត ភាពស្មោះត្រង់ និងឆន្ទៈ របស់អតិថិជន ក្នុងការបង់សងមកវិញ
2. ផ្តល់បរិមាណកម្ចីដែលសមស្របជាមួយនឹងលទ្ធភាពសងរបស់អតិថិជន
3. រៀបចំផែនការសំរាប់ករណីបំពានកាតព្វកិច្ចឥណទាន
4. ផ្តល់ឥណទាន ត្រឹមកំរិតដែលអាចយល់ និងគ្រប់គ្រងហានិភ័យបាន
5. ធានាឲ្យមានការចូលរួមឥតលម្អៀងក្នុងដំណើរការឥណទាន
6. ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ចំពោះគ្រប់សកម្មភាព
7. ប្រកាន់យកនូវការទប់ស្កាត់ជាមុនដោយធ្វើការកំណត់ គ្រប់គ្រង និងបង្កើនសមត្ថភាពយល់ដឹងអំពីហានិភ័យឥណទាន
8. យកចិត្តទុកដាក់ និងមានការប្រុងប្រយ័ត្នខ្ពស់ដើម្បីធានាថារាល់សកម្មភាព និងការប្រឈមនឹងហានិភ័យត្រូវបានអនុវត្តទៅតាមតម្រូវការនៃគោលនយោបាយរបស់ក្រុមហ៊ុន។
9. ធ្វើឲ្យមានតុល្យភាពរវាងហានិភ័យ និងផលចំណេញ
10. បង្កើន និងរក្សាផលប័ត្រហានិភ័យឥណទានសំបូរបែប

## ភាពជាដៃគូ



ក្រុមហ៊ុន ហ្វីស ហ្វាយនែន បានបង្កើតភាពជាដៃគូជាមួយស្ថាប័នជាច្រើនដូចខាងក្រោមដើម្បីសម្រេចបេសកកម្ម និងទស្សនៈវិស័យរបស់ក្រុមហ៊ុន៖

- ក្រុមហ៊ុនសាងសង់ផ្ទះដែលមានតម្លៃទាប និងមធ្យម និងក្រុមហ៊ុនអចលនទ្រព្យ
- ក្រុមហ៊ុនសាងសង់ និងរចនា
- ស្ថាប័ន អង្គការផ្សេងៗដែលមានគោលដៅផ្តល់ទីជំរកជូនប្រជាជនកម្ពុជាដែលមានចំណូលទាប
- អង្គការដែលផ្តោតជាសំខាន់លើការងារសង្គម
- គ្រឹះស្ថានហិរញ្ញវត្ថុ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ, ក្រុមហ៊ុនធានារ៉ាប់រង, ធនាគារ)
- វិទ្យាស្ថានអប់រំ (សាលា និងសាកលវិទ្យាល័យ)

## សេវាកម្មហិរញ្ញប្បទានថ្មីបង្កើតក្នុងឆ្នាំ




ឥណទានទិញសំភារៈក្នុងផ្ទះ គឺជាសេវាកម្មថ្មីមួយដែលត្រូវបានបន្ថែមចូលជាមួយនឹងសេវាកម្មហិរញ្ញប្បទានផ្ទះសម្បែង ក្នុងគោលបំណងជួយដល់អតិថិជនរបស់ក្រុមហ៊ុនដើម្បីមានលទ្ធភាពទិញសំភារៈសំខាន់ៗប្រើប្រាស់ក្នុងផ្ទះដែលជួយសម្រួលដល់ពួកគាត់ក្នុងការរស់នៅប្រកបដោយផលិតភាពខ្ពស់ និងការសន្សំសំចៃ ។

## ចំនួនកម្ចីសកម្ម




## ភាគរយនៃចំនួនអតិថិជនតាមរយៈចំណូលប្រចាំខែ



# សាវតារបស់វិនិយោគិន/ភាគទុនិក

PhillipCapital
Your Partner In Finance

### POEMS PTE LTD គឺជាក្រុមហ៊ុនវិនិយោគរបស់ PHILLIPCAPITAL GROUP.

ក្រុមហ៊ុន Phillip Capital ដែលបានបង្កើតឡើងនៅប្រទេសសិង្ហបុរីក្នុងឆ្នាំ១៩៧៥ បច្ចុប្បន្នបានក្លាយជាមជ្ឈមណ្ឌលហិរញ្ញវត្ថុ ប្រចាំតំបន់អាស៊ី ដែលផ្តល់នូវគ្រប់សេវាហិរញ្ញវត្ថុ ដែលប្រកបដោយគុណភាព និងភាពច្នៃប្រឌិតខ្ពស់ ដល់អតិថិជន ដែលជាស្ថាប័នសាជីវកម្ម និងលក់រាយ។ សេវាហិរញ្ញវត្ថុដ៏ទូលំទូលាយទាំងនេះ រួមមានជាអាទិ៍៖ ការគ្រប់គ្រងមូលនិធិ មូលធនវិនិយោគ វិភាគហ៊ុនឯកជន ការផ្តល់ហិរញ្ញប្បទាន លើបំណុលទីផ្សារស្ថាប័ន និងសាជីវកម្ម សេវាគ្រប់គ្រងទ្រព្យសម្បត្តិ ការពិគ្រោះយោបល់ និងហិរញ្ញប្បទានដល់សាជីវកម្ម ដំណោះស្រាយព័ត៌មានវិទ្យា បរធនបាលកិច្ចមូលប័ត្រ ការទិញទុកមូលនិធិ គំរោងធានារ៉ាប់រង ការស្រាវជ្រាវវិនិយោគជំនួញឈ្មួញកណ្តាលនូវប័ណ្ណ បំណុល មូលប័ត្រអនាគត ដំណូររូបិយប័ណ្ណ លោហធាតុមានតម្លៃ និងទំនិញផ្សេងៗ ព្រមទាំងអចលនទ្រព្យ ។ បច្ចុប្បន្ន Phillip Capital មានបុគ្គលិកជាង ២៨០០នាក់នៅក្នុងទ្វីបអាស៊ី និងអឺរ៉ុប ហើយទឹកប្រាក់មូលនិធិសរុប របស់ភាគទុននិកទាំងអស់មានជាង ៧០០លានដុល្លាអាមេរិក។ ក្រុមហ៊ុនមានប្រតិបត្តិការនៅប្រទេសចំនួន១០ គឺ៖ សិង្ហបុរី ចក្រភពអង់គ្លេស បារាំង ចិន ហុងកុង ថៃ ជប៉ុន អូស្ត្រាលី ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី។ នៅសិង្ហបុរី សមាជិករបស់ Phillip Capital រួមមាន៖ Phillip Securities, Phillip Securities Research, Phillip Futures, Phillip Financial, Phillip Capital Management, Cyber Quote, Phillip Private Equity, Phillip Trading, IFS Capital Limited និង ECICS Limited.

INSITOR FUND Seed Capital For Development

Insitor Fund SCA គឺជាមូលនិធិ មូលធនសង្គមមួយដែលផ្តល់មូលធនដល់សហគ្រិនសង្គមដែល មានភាពវៃឆ្លាត និងផ្តល់ដំណោះស្រាយដល់បណ្តាបញ្ហាអភិវឌ្ឍន៍សំខាន់ៗ ហើយជំរុញឱ្យមាន សេដ្ឋកិច្ចមួយដែលប្រកបទៅដោយទំនួលខុសត្រូវ និងនិរន្តភាព ។ Insitor ផ្តោតយកចិត្តទុកដាក់ដល់បណ្តាសហគ្រាសដែលផ្តល់ដំណោះស្រាយជាដំណាក់កាល និងដែលអាចទុកចិត្តបានដើម្បី បង្កើតលទ្ធភាពឱ្យប្រជាជនដែលមានចំណូលទាបអាចទទួលបាននូវផលិតផល និងសេវាជា មូលដ្ឋានទាំងឡាយ ដូចជាផ្ទះសម្បែង ទឹក ការអប់រំ និងសុខភាពជាដើម ។
Insitor ធ្វើការវិនិយោគយ៉ាងមឺងម៉ាត់នូវមូលនិធិ មូលធនសំរាប់ប្រាក់ចំណេញ ដោយមានការរំពឹងថា នឹងទទួលបាននូវការផ្លាស់ប្តូរសង្គមជាវិជ្ជមាន □ ហើយមានការអំណត់ និងទំនួលខុសត្រូវក្នុងការ រកប្រាក់កម្រៃហិរញ្ញវត្ថុ។ Insitor មានជំនឿយ៉ាងមុតមាំថា ការយល់ឱ្យបានស៊ីជម្រៅនូវបរិបទសង្គមនយោបាយ អាជីវកម្ម និងបទបញ្ញត្តិ របស់អ្នកដែលបានទទួលប្រាក់វិនិយោគ គឺជាកត្តាសំខាន់ក្នុងការធានាឱ្យបានថា រាល់ទិន្នន័យបច្ចេកទេសមានភាពប្រាកដនិយម ស្ថាបនា និងអាចធ្វើសកម្មភាពបាន។

### FIRST HOME PLC

First Home Plc ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ជាក្រុមហ៊ុនដែលផ្តល់នូវដំណោះស្រាយ ផ្ទះសម្បែង ដោយមានបេសកកម្មសង្គមក្នុងការបង្កើននូវឱកាសក្លាយជាម្ចាស់ផ្ទះលើកទីមួយ។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើង ដោយបុគ្គលមួយចំនួនដែលមាន វិជ្ជាជីវៈ និងគំនិតជួយសង្គម ក្នុងគោលបំណងជួយក្រុមគ្រួសារខ្មែរដែលមានចំណូលទាប និងមធ្យមឱ្យបានក្លាយជាម្ចាស់ផ្ទះ ដំបូងរបស់គេ។ គំនិតនៃផលិតផល ឥណទានផ្ទះសម្បែង និងឥណទានសាងសង់ ជួសជុលផ្ទះ ក៏ត្រូវបានបង្កើតឡើង ហើយនឹងសាកល្បងបានជោគជ័យទៀតផង។ បទពិសោធន៍នៃភាព ជោគជ័យនេះ ក៏នាំឱ្យមានការបង្កើតឡើងនូវក្រុមហ៊ុន First Finance Plc ។ ជាលទ្ធផលនៃការប្រឹងប្រែង និងប្តេជ្ញាចិត្តរបស់សមាជិកក្រុមប្រឹក្សាភិបាលនៃ First Home នោះ First Finance ក៏ទទួលបានអាជ្ញាប័ណ្ណ ពីធនាគារជាតិ ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០០៩។
First Home មានចំណេះដឹងទូលំទូលាយអំពីទីផ្សារក្នុងស្រុក យល់ពីនិន្នាការ និងតម្រូវការទីផ្សារ ក្នុងស្រុក តម្រូវការបញ្ញត្តិច្បាប់ តម្រូវការសង្គម និងមានបណ្តាញទំនាក់ទំនងក្នុងស្រុក យ៉ាងរឹងមាំផង។

CLDF Cambodia-Laos Development Fund

មូលនិធិអភិវឌ្ឍន៍កម្ពុជា ឡាវ SCA “CLDF SCA, SICAV-SIF” គឺជាមូលនិធិឯកទេសខាងវិនិយោគដែលមានការិយាល័យក្នុងប្រទេសលុចសំបួ ដែលស្វែងរកនូវចំណូលហិរញ្ញវត្ថុសមស្របជូនអ្នកវិនិយោគទុនរបស់ខ្លួន ដោយការធ្វើវិនិយោគក្នុងអាជីវកម្មដែលប្រកបដោយភាពច្នៃប្រឌិត និងតម្លាភាព នៅក្នុងប្រទេសកម្ពុជា និងឡាវ ។ តាមរយៈការធ្វើវិនិយោគនូវមូលនិធិមូលធន ទៅលើវិស័យកង្វះខាតហិរញ្ញវត្ថុសំខាន់មួយនេះ មូលនិធិនេះមានបំណងចង់ឲ្យមានផលវិជ្ជមានទៅលើដំណើរការអភិវឌ្ឍន៍វិស័យឯកជនក្នុងតំបន់នេះ ។

# ប្រវត្តិក្រុមហ៊ុន ហ្វឹស ហ្វាយនែន ភីអិលស៊ី

## ទស្សនៈវិស័យរបស់ក្រុមហ៊ុន

យើងមានជំនឿថាមនុស្សគ្រប់រូបត្រូវមានឱកាស ដើម្បីរស់នៅក្នុងជីវិតមួយដ៏សមរម្យ និងថ្លៃថ្នូរ ហើយជីវិតបែបនេះត្រូវតែមានផ្ទះ និងគ្រួសារដែលមានភាពកក់ក្តៅ និងសុវត្ថិភាព ។ ទស្សនៈ វិស័យរយៈពេលវែងរបស់ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ភីអិលស៊ី គឺជួយគ្រួសារខ្មែរ អោយបានរស់នៅក្នុងភាពថ្លៃថ្នូរ សន្តិសុខ សុភមង្គល និងស្ថេរភាព តាមរយៈការផ្តល់ លទ្ធិភាពអោយបានក្លាយជាម្ចាស់កម្មសិទ្ធិផ្ទះ សម្បែងដោយមិនប្រកាន់ឋានៈនិង វណ្ណៈក្នុងសង្គមឡើយ។

## បេសកម្មរបស់ក្រុមហ៊ុន

ដើម្បីបង្កើតស្ថេរភាពសេដ្ឋកិច្ច និងជីវភាពនៃគ្រួសារខ្មែរ ដែលមានចំនូលទាប តាមរយៈការផ្តល់លទ្ធិភាព និងឱកាសក្លាយជាម្ចាស់កម្មសិទ្ធិនៃផ្ទះសម្បែង។

## សេវាកម្ម

ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ភីអិលស៊ី មានផ្តល់ជូននូវសេវាកម្មហិរញ្ញប្បទានផ្ទះសម្បែងបីយ៉ាងដូចខាងក្រោមនេះ

**១. ឥណទានផ្ទះសម្បែង:** សំរាប់ទិញលំនៅដ្ឋានលើកទីមួយ

- អត្រាការប្រាក់ប្រចាំឆ្នាំមានភាពប្រកួតប្រជែង
- ការសងរំលោះថេរប្រចាំខែ
- អាចខ្ចីបានរហូតដល់រយៈពេល ១៥ឆ្នាំ
- ទទួលយកទាំងប្លង់ទន់ និង ប្លង់រឹងសំរាប់អចលនទ្រព្យដាក់បញ្ចាំ

**២. ឥណទានសំរាប់សាងសង់ រឺជួសជុលផ្ទះ:** សម្រាប់សាងសង់ ជួសជុលកែលំអរ និងពង្រីកផ្ទះ

- អត្រាការប្រាក់ប្រចាំឆ្នាំមានភាពប្រកួតប្រជែង
- ការសងរំលោះថេរប្រចាំខែ
- អាចខ្ចីបានរហូតដល់រយៈពេល ១០ឆ្នាំ
- ទទួលយកទាំងប្លង់ទន់ និង ប្លង់រឹងសំរាប់អចលនទ្រព្យដាក់ញ្ចាំ

**៣. ឥណទានទិញសំភារៈគេហដ្ឋាន**

- ជាឥណទានសំរាប់ទិញសំភារៈគេហដ្ឋាន ដើម្បីភ្ជាប់ជាមួយនឹងសេវាកម្មហិរញ្ញប្បទានផ្ទះសម្បែង (ឥណទានសំរាប់ទិញលំនៅដ្ឋានលើកទី១ និងឥណទានសំរាប់សាងសង់ ជួសជុលផ្ទះ)
- អត្រាការប្រាក់ប្រចាំឆ្នាំមានភាពប្រកួតប្រជែង
- អាចខ្ចីបានរហូតដល់រយៈពេល ៥ឆ្នាំ
- ទ្រព្យធានាគឺអចលនទ្រព្យដែលបានដាក់បញ្ចាំជាមួយគ្រឹះស្ថាននៅពេលស្នើសុំឥណទានសំរាប់ទិញផ្ទះ រឺសាងសង់ ជួសជុលផ្ទះ។

## ទស្សនៈក្រុមហ៊ុន

ទស្សនៈក្រុមហ៊ុនយើងមានលក្ខណៈសាមញ្ញពោលគឺ យើងគិតក្នុងនាមជាអតិថិជន ហើយប្រតិបត្តិក្នុងនាមជាម្ចាស់ក្រុមហ៊ុន ហើយវិធីសាស្ត្រក្នុងការការអនុវត្តន៍ របស់យើងកាន់តែងាយស្រួលដូចបានសង្ខេបខាងក្រោម:

- សេវាកម្មដែលស្របទៅតាមតំរូវការទីផ្សារ
- បែបបទដាក់ពាក្យសុំ និងនីតិវិធីអនុម័តឥណទានមានភាពងាយស្រួល និងរហ័សទាន់ចិត្ត
- ប្រតិបត្តិការមានតម្លាភាព និងស្របតាមតម្រូវការ

## រចនាសម្ព័ន្ធគ្រប់គ្រង




## ការវិវឌ្ឍន៍របស់ក្រុមហ៊ុន








# សាវតារបស់សមា-ជិកក្រុមប្រឹក្សាភិបាល

### 1. TALMAGE MARK PAYNE, ជាប្រធានក្រុមប្រឹក្សាភិបាលមកពីសហរដ្ឋអាមេរិក

- ជាអគ្គនាយក នៃអង្គការ Hagar Cambodia
- ជាស្ថាបនិក នៃក្រុមហ៊ុន First Home Plc.
- ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Vision Fund Cambodia
- ជានាយកប្រចាំប្រទេស នៃអង្គការ World Vision Cambodia
- មានបទពិសោធន៍ការងារ ១៥ ឆ្នាំ នៅក្នុងប្រទេសកម្ពុជាជាពិសេសក្នុងការងារបំរើសង្គម

### 2. MICAELA RATINI, ជាសមាជិកក្រុមប្រឹក្សាភិបាលមកពីប្រទេសអ៊ីតាលី

- ជាស្ថាបនិកនៃមូលនិធិមូលធនសង្គមអន្តរជាតិទីមួយរបស់ប្រទេសអ៊ីតាលី
- មានបទពិសោធន៍ ៧ ឆ្នាំ ជានាយកជាន់ខ្ពស់នៅក្រុមហ៊ុន Bain & Co ផ្តោតលើវិស័យធនាគារ
- មានបទពិសោធន៍ 10 ឆ្នាំជាអ្នកឯកទេសជាន់ខ្ពស់ក្នុងឧស្សាហកម្មហិរញ្ញវត្ថុ
- មានបទពិសោធន៍ទូលំទូលាយក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍

### 3. NICHOLAS JOHN LAZOS, ជាសមាជិកក្រុមប្រឹក្សាភិបាលមកពីប្រទេសអ៊ីតាលី

- ជាប្រធានផ្នែកវិនិយោគនៃក្រុមហ៊ុន Insitor Fund SCA
- មានបទពិសោធន៍ការងារផ្នែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរាប់បញ្ចូលទាំងការគ្រប់គ្រងក្រុមហ៊ុន First Home Plc

### 4. MICHAEL TAN TECK KOEUNG, ជាសមាជិកក្រុមប្រឹក្សាភិបាលមកពីប្រទេសសិង្ហបុរី

- ជាសមាជិកក្រុមប្រឹក្សាភិបាល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត កម្ពុជា
- ទីប្រឹក្សាបច្ចេកទេសនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ CBIRD កម្ពុជា
- ជានាយកផ្នែកអភិវឌ្ឍន៍សាជីវកម្ម Phillip Securities Pte. Ltd. តាំងពីឆ្នាំ ២០០៨
- មានបទពិសោធន៍ជាង ២០ ឆ្នាំ ក្នុងវិស័យឧស្សាហកម្ម និងបរិយាការបណ្ឌិតសភា រួមមាន ជាជំនួយការសាស្ត្រាចារ្យនៅ University of Nevada សហរដ្ឋអាមេរិច, សាស្ត្រចារ្យនៅសាកលវិទ្យាល័យជាតិសឹង្ហបូរី, មានបទពិសោធន៍ផ្នែកគ្រប់គ្រងព័ត៌មានវិទ្យា និងមន្ត្រីប្រឹក្សាយោបល់នៅប្រទេសសឹង្ហបូរី

### 5. ONG TEONG HOON, ជាសមាជិកក្រុមប្រឹក្សាភិបាលមកពីប្រទេសសិង្ហបុរី

- ជានាយកជាន់ខ្ពស់នៃក្រុមហ៊ុន Phillip Capital
- មានបទពិសោធន៍ការងារជាង ២៥ ឆ្នាំ ជាមួយធនាគារ Standard Charter Bank
- ជាស្ថាបនិកនៃអង្គការ Hagar Design Pte. Ltd.
- ជានាយកអង្គការ Prison Fellowship Sigapore
- ជាបណ្ណាធិការរងនៃអង្គការ Boy Brigade នៅសិង្ហបូរី






# សាវតាសមាជិក គណគ្រប់គ្រង

## 1. លឹម ហាក់យុន ជាអគ្គនាយក

- សញ្ជាតិខ្មែរបញ្ចប់ការសិក្សានៅប្រទេសកម្ពុជា និងកាណាដា
- បញ្ចប់ការសិក្សាផ្នែកពាណិជ្ជកម្មនៅ York University ក្រុង Toronto ប្រទេសកាណាដា
- ជំនាញឯកទេសលើភាសាទំនាក់ទំនងដូចជា ខ្មែរ អង់គ្លេស បារាំង ចិន (Mandarin, Cantonese, Teochew dialects) វៀតណាម និងថៃ
- មានបទពិសោធន៍ការងារជាង ១៦ឆ្នាំ រួមមាន ១១ ឆ្នាំ ផ្នែកធនាគារ

- ជាប្រធានតំបន់នៃធនាគារ ANZ Royal Bank
- ជាប្រធានផ្នែកលក់នៃធនាគារ Maruhan Japan Bank
- ជាប្រធានផ្នែកឥណទាននៃធនាគារ Vattanac Bank
- ជាប្រធានផ្នែកសាជីវកម្មនៃធនាគារ Standard Chartered Bank
- ជាប្រធានផ្នែកហានិភ័យនៃក្រុមហ៊ុនធានារ៉ាប់រង Forte Insurance
- ជាគ្រូបង្រៀន និងមន្ត្រីរដ្ឋបាលនៃ Regent College
- អ្នកសម្របសម្រួលគំរោងនៃសមាគមន៍ ខ្មែរ-កាណាដា ប្រចាំ Ontario

## 2. ជុន សុថានី ជានាយកផ្នែកហិរញ្ញវត្ថុ

- សញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារជាអ្នកគ្រប់គ្រងរយៈពេល ៨ ឆ្នាំ
- អតីតប្រធានផ្នែកប្រតិបត្តិ នៃក្រុមហ៊ុន Wing Cambodia
- អតីតប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម នៃក្រុមហ៊ុន Vision Fund Cambodia
- អតីតប្រធានផ្នែកធនធាន និង សវនករផ្ទៃក្នុង នៃអង្គការ World Vision Cambodia

## 3. ហ្សាង សភា ជាប្រធានផ្នែកឥណទាននិងរដ្ឋបាល

- សញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកគណនេយ្យ / ហិរញ្ញវត្ថុ
- សញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកភាសាបារាំង
- មានបទពីសោធន៍ការងារលើស ៦ ឆ្នាំ
- អតីតមន្ត្រីសម្របសម្រួលប្រតិបត្តិការ នៃក្រុមហ៊ុន First Home Plc

## 4. ឈួរ សិបូរ ជាសវនករផ្ទៃក្នុងជាន់ខ្ពស់

- កំពុងសិក្សាបន្តក្នុងកម្មវិធីសិក្សា ACCA/ CPA
- សញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ
- អតីតប្រធានសវនករផ្ទៃក្នុង នៃក្រុមហ៊ុន Lim Heng Group
- អតីតសវនករឯករាជ្យ នៃក្រុមហ៊ុន PriceWaterhouse Cooper

## 5. ងី មករា ជាប្រធានពត៏មានវិទ្យា

- សញ្ញាប័ត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រ និងវិស្វកម្មកំព្យូទ័រ
- សញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកអក្សរសាស្ត្រអង់គ្លេស
- មានបទពិសោធន៍ការងារជាអ្នកគ្រប់គ្រងរយៈពេល ៦ឆ្នាំ
- អតីតប្រធាន IT នៃធនាគារ Booyoung Khmer
- អតីតប្រធាន IT នៃធនាគារកម្ពុជាអាស៊ី

# គណៈកម្មការក្រុមប្រឹក្សាភិបាល

## ក. គណៈកម្មការសវនកម្ម និងប្រតិបត្តិការ

គណកម្មការសវនកម្ម និងប្រតិបត្តិការ ត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយក្រុមប្រឹក្សាភិបាល ក្នុងការបំពេញតួនាទីរបស់ខ្លួនលើទំនួលខុសត្រូវផ្នែកអភិបាលកិច្ចរបស់គ្រឹះស្ថានដោយការយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ទៅលើ៖

- របាយការណ៍ហិរញ្ញវត្ថុ
- គោលនយោបាយគណនេយ្យ
- ការរក្សានូវឯករាជភាពរបស់សវនករក្រុមហ៊ុន
- ការគ្រប់គ្រងហិរញ្ញវត្ថុ
- ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង
- ការគ្រប់គ្រងហានិភ័យ
- ការពិនិត្យពិច័យលើករណីក្លែងបន្លំ
- ការប្រតិបត្តិតាមបញ្ញត្តិ និងគោលការណែនាំពាក់ព័ន្ធផ្សេងៗ

គណកម្មការសវនកម្ម មានសមាសភាពដូចខាងក្រោម៖

### 1. ONG TEONG HOON, ជាប្រធាន

- នាយកជាន់ខ្ពស់នៃក្រុមហ៊ុន Phillip Capital
- មានបទពិសោធន៍ការងារជាង២៥ ឆ្នាំជាមួយធនាគារ Standard Chartered Bank
- ជាស្ថាបនិកនៃអង្គការ Hagar Design Pte. Ltd.
- ជានាយកអង្គការ Prison Fellowship Singapore
- ជាបណ្ណាធិការរងនៃអង្គការ Boy Brigade នៅសិង្ហបូរី

### 2. RANNY CHUNG, ជាសមាជិក

- ជានាយកនៃក្រុមហ៊ុន Fides Services Cambodia នៅភ្នំពេញ (២០០៣ រហូតដល់បច្ចុប្បន្ន)
- សញ្ជាតិខ្មែរបញ្ចប់ការសិក្សានៅប្រទេសណូវែលស្សេឡង់
- ជាគណនេយ្យករជំនាញ (CPA)
- អតីតប្រធានប្រចាំប្រទេសនៃក្រុមហ៊ុន KPMG Cambodia
- អតីតប្រធានសវនករជានខ្ពស់នៃក្រុមហ៊ន KPMG, Wellington, New Zealand

### 3. KAY LOT, ជាសមាជិក

- នាយកប្រតិបត្តិនៃក្រុមហ៊ុន CamGSM
- មានបទពិសោធន៍ជាង ១៣ ឆ្នាំផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ
- អតីតប្រធានផ្តត់ផ្គង់សេវាកម្មនៃធនាគារ Standard Chartered Bank Cambodia
- សញ្ញប័ត្របរិញ្ញាប័ត្រវិទ្យាសាស្រ្ត ពីសកលវិទ្យាល័យ Warren National University, Idaho USA

## ខ. គណៈកម្មការហានិភ័យ

គណកម្មការហានិភ័យ ត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយក្រុមប្រឹក្សាភិបាលក្នុងការបំពេញតួនាទីរបស់ខ្លួនលើទំនួលខុសត្រូវផ្នែកអភិបាលកិច្ចរបស់គ្រឹះស្ថាន ដោយការយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ទៅលើ៖

- ការគ្រប់គ្រងដើមទុនរយៈពេលវែង និងការព្យាករណ៍
- គោលនយោបាយអត្រាការប្រាក់
- ហានិភ័យប្រតិបត្តិការ និងក្នុងប្រទេស (ហានិភ័យក្រៅអំពីហិរញ្ញវត្ថុ)
- បង្កើតគោលការណ៍ហានិភ័យ និងនិតិវិធី សំរាប់គណៈគ្រប់គ្រង
- គោលនយោបាយឥណទាន
- គោលនយោបាយទ្រព្យសកម្ម - ទ្រព្យអកម្ម
- គោលនយោបាយគ្រប់គ្រងហានិភ័យគណកម្មការហានិភ័យ មានសមាសភាពដូចខាងក្រោម:

### 1. NICHOLAS JOHN LAZOS, ជាប្រធាន

- ជាប្រធានផ្នែកវិនិយោគនៃក្រុមហ៊ុន Insitor Fund SCA
- មានបទពិសោធន៍ការងារផ្នែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរាប់បញ្ចូលទាំងការគ្រប់គ្រងក្រុមហ៊ុន First Home Plc

### 2. MICHAEL TAN TECK KEONG, ជាសមាជិក

- ជាសមាជិកក្រុមប្រឹក្សាភិបាល គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ក្រេឌីត កម្ពុជា
- ទីប្រឹក្សាបច្ចេកទេសនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ CBIRD កម្ពុជា
- ជានាយកផ្នែកអភិវឌ្ឍន៍សាជីវកម្ម Phillip Securities Pte. Ltd. តាំងពីឆ្នាំ ២០០៨
- មានបទពិសោធន៍ជាង ២០ ឆ្នាំ ក្នុងវិស័យ ឧស្សាហកម្ម និងបរិយាការបណ្ឌិតសភា រួមមាន ជាជំនួយការសាស្រ្តាចារ្យនៅ University of Nevada សហរដ្ឋអាមេរិច, សាស្រ្តចារ្យនៅសាកលវិទ្យាល័យជាតិសឹង្ហបូរី មានបទពិសោធន៍ផ្នែកគ្រប់គ្រងព័ត៌មានវិទ្យា និង មន្រ្តីប្រឹក្សាយោបល់នៅ ប្រទេសសឹង្ហបូរី



## ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក

➲ ពង្រឹងសមត្ថភាពបុគ្គលិកតាមរយៈស្ថាប័នជំនាញ ខាងបណ្តុះបណ្តាលផ្នែកគ្រប់គ្រងធនធានមនុស្ស គណនេយ្យ/ហិរញ្ញវត្ថុ ផ្នែកគ្រប់គ្រង និងភាពជាអ្នកដឹកនាំ។

➲ ពង្រឹងសមត្ថភាពបុគ្គលិកតាមរយៈ សិក្ខាសាលាអំពីពន្ធដារ អភិបាលកិច្ច ចំណេះដឹងខាងមូលប័ត្រ ការប្តូររូបិយប័ណ្ណបរទេស។

➲ ការបណ្តុះបណ្តាលនៅក្នុងក្រុមហ៊ុនផ្ទាល់មានដូចជា៖

- កិច្ចការពារអតិថិជន
- ដំណើរការលក់ និងយុទ្ធសាស្រ្តទីផ្សារ
- ផ្នែកបម្រើអតិថិជន
- ក្រុមសីលធម៌ /ក្រុមអនុវត្តន៍អាជីវកម្ម
- វិធីសាស្រ្តនៃការវាយតម្លៃអចលនទ្រព្យ



## សេវាកម្មអតិថិជន

នៅពេលនិយាយអំពីសេវាកម្មអតិថិជន " **អតិថិជនជាអាទិភាព** " គឺជាទស្សនៈចម្បងរបស់យើង។ នៅហ្វីស ហ្វាយនែន អតិថិជនគ្រប់ស្រទាប់វណ្ណៈបានទទួលស្វាគមន៍យ៉ាងរាក់ទាក់ដោយគ្មានការរើសអើងអំពីបុគ្គលិកដែលបានឆ្លងកាត់ការបណ្តុះបណ្តាលយ៉ាងល្អ។

នៅពេលដែលអ្នកចូលដល់បរិវេនខាងក្នុងរបស់ក្រុមហ៊ុន ហ្វីស ហ្វាយនែន អ្នកនឹងទទួលបានការរៀបចំទទួលដោយសោមនស្ស ជាមួយនឹងទឹកមុខញញឹមធម្មជាតិពីសំណាក់មន្រ្តីសេវាកម្មអតិថិជនរបស់យើងខ្ញុំ។







# ការចូលរួមចំណែកក្នុងសង្គម

លោក លីម ដារ៉ា ជាមួយនឹង ភរិយា ព្រមទាំងបុត្រចំនួន ២នាក់ ធ្លាប់បានរស់នៅក្នុងតំបន់បឹងកក់ដែលប្រឈមនឹងការបណ្តេញចេញ។ លោក លីម ដារ៉ាគឺជាអ្នកបើកបររថយន្តឲ្យក្រុមហ៊ុនមួយនៅក្នុងរាជធានីភ្នំពេញ ហើយភរិយារបស់គាត់ គឺលោកស្រី យន់ វន្នី ប្រកបអាជីវកម្មជាជាងកាត់ដេរដោយខ្លួនឯងផ្ទាល់នៅផ្ទះរបស់ខ្លួន។ តាមរយៈកម្មវិធីសាងសង់ ជួសជុលផ្ទះរបស់ក្រុមហ៊ុន ហ្វីស ហ្វានែន គ្រួសាររបស់គាត់បានសាងសង់ផ្ទះថ្មីទីមួយលើដីរបស់ខ្លួននៅសហគមន៍នគរថ្មី ស្ថិតក្នុង ខណ្ឌ ពោធិ៍សែនជ័យ។ ការរស់នៅរបស់ក្រុមគ្រួសារគាត់បានផ្លាស់ប្តូរ ដោយពួកគាត់រស់នៅយ៉ាងមានសុភមង្គល នៅក្នុងផ្ទះថ្មីរបស់ខ្លួនដោយមិនចាំបាច់ព្រួយបារម្ភអំពីការបណ្តេញចេញទៀតឡើយ។



លោក ម៉ែន វ៉ាន់ និងភរិយា សុខ តី ព្រមទាំងបុត្រចំនួន ៣នាក់ មានស្រុកកំណើត នៅឯខេត្តស្វាយរៀង។ ដើម្បីពង្រឹងជីវភាពរស់នៅរបស់គ្រួសារ លោក ម៉ែន វ៉ាន់ បានចាកចេញពីស្រុកកំណើតរបស់ខ្លួន ហើយមករស់នៅក្នុងផ្ទះជួលមួយនៅរាជធានីភ្នំពេញ អស់រយៈពេលជាង ៣ឆ្នាំ។ បច្ចុប្បន្ន លោក ម៉ែន វ៉ាន់ គឺជាមេជាងសំណង់ ហើយភរិយារបស់គាត់ជាកម្មករកាត់ដេរនៅក្នុងរោងចក្រកាត់ដេរមួយ។ កាលពីអំឡុង ខែកុម្ភៈ ២០១២ ពួកគាត់បានសម្រេចចិត្តទិញផ្ទះថ្មីមួយ នៅក្នុងបុរីសែនសុខ (ចោមចៅ) តាមរយៈឥណទានផ្ទះសម្បែងរបស់ក្រុមហ៊ុនហ្វីស ហ្វាយនែន។ ជាមួយនឹងភាពជាកម្មសិទ្ធិផ្ទះនេះ គ្រួសារលោក ម៉ែន វ៉ាន់ បានបង្វែរប្រាក់ចំណាយប្រចាំខែលើការជួលផ្ទះ មកជាការវិនិយោគរយៈពេលវែងវិញ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានក្តីសោមនស្សរីករាយក្នុងការដាក់ជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា (ក្រុមហ៊ុន) ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 ។

## សកម្មភាពចំបង

សកម្មភាពចំបងរបស់ក្រុមហ៊ុន គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុសម្រាប់ទិញលំនៅដ្ឋានដំបូងដល់គ្រួសារដែលមានចំណូលមធ្យម និងទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 មានដូចខាង ក្រោម:

| | ដុល្លារអាមេរិក |
|---|---:|
| ប្រាក់ចំណេញមុនបង់ពន្ធ | 148,226 |
| ពន្ធលើប្រាក់ចំណេញ | (32,076) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | **116,150** |

## ទុនបំរុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបំរុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថារាល់ឥណទានដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើយ៉ាងគ្រប់គ្រាន់សម្រាប់ឥណទានដែលជាប់សង្ស័យ ។
គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កំរិតជាសារវន្តណាមួយ នោះទេ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់ វិធានការណ៍ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានជាក់ស្តែង ។
នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ាះទេ ។



# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ដើមទុន

នៅថ្ងៃទី 25 ខែមិនា ឆ្នាំ2011 ក្រុមហ៊ុនបានបង្កើនដើមទុនរបស់ខ្លួនពី 300,000 ដុល្លារអាមេរិក ដល់ 2,289,370 ដុល្លារអាមេរិក តាមរយៈការបង្វែរពីប្រាក់កម្ចីចំនួន 1,989,370 ដុល្លារអាមេរិក ។
រចនាសម្ព័ន្ធដើមទុន និងសេចក្តីលំអិតអំពីភាគហ៊ុនដែលបានអនុម័ត និងចុះបញ្ជីមានដូចខាងក្រោម:

| | | 2011 | | | 2010 | |
|---|---:|---:|---:|---:|---:|---:|
| | ភាគរយរបស់ ភាគហ៊ុន | ចំនួន ភាគហ៊ុន | ដុល្លា អាមេរិក | ភាគរយរបស់ ភាគហ៊ុន | ចំនួន ភាគហ៊ុន | ដុល្លា អាមេរិក |
| Insitor Fund SCA | 42.63 | 976,000 | 976,000 | - | - | - |
| Poems Pte Ltd | 42.63 | 976,000 | 976,000 | - | - | - |
| First Home Plc | 14.74 | 337,370 | 337,370 | 100 | 300,000 | 300,000 |
| | 100 | 2,289,370 | 2,289,370 | 100 | 300,000 | 300,000 |

ការធ្វើវិសោធនកម្មលើអនុស្សារណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 4 ខែកក្កដា ឆ្នាំ 2011 និងធនាគារជាតិនៃកម្ពុជានៅថ្ងៃទី18 ខែមិថុនា ឆ្នាំ 2011។

## វិធីសាស្រ្តកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្រ្ត ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និង បំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះ

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន:
(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ មកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ។
(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ មកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។
ក្រុមប្រឹក្សាភិបាលមានយោបល់ថា ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់នៃការិយបរិច្ឆេទដែលនឹងមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ច របស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់ ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានរែកញែក នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលនឹងបណ្តាលឱ្យមានតួលេខនៃ ចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាល មានយោបល់ថាលទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនត្រូវបានប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមាន លក្ខណៈជាសារវ័ន្ត និងមិនប្រក្រតីនោះទេ ។
ក្រុមប្រឹក្សាភិបាលក៏មានយោបល់ផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញ របាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈ ជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានៈ

- លោក **Talmage Mark Payne** ប្រធាន
- អ្នកស្រី **Micaela Ratini** អភិបាល
- លោក **Ong Teong Hoon** អភិបាល
- លោក **Michael Tan Teck Keong** អភិបាល ( លាលែងនៅថ្ងៃទី 27 ខែ មិថុនា ឆ្នាំ 2011 )
- លោក **Nicholas John Lazos** អភិបាល

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃតារាងតុល្យការ

ពុំមានព្រឹត្តិការណ៍សំខាន់ៗ កើតមានឡើងនៅក្រោយកាលបរិច្ឆេទនៃតារាងតុល្យការ ដែលតម្រូវឲ្យមាន ការបង្ហាញ ឬការធ្វើនិយ័តកម្មនោះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងនិងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីក្នុង គោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយ នៃការទិញយកភាគហ៊ុន ឬលិខិតឥណទាន ឬពីក្រុមហ៊ុនដទៃទៀតទេ ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុកន្លងទៅ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនណា ម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅអំពីអត្ថប្រយោជន៍ដែលបាន ទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ)តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធមួយ ជាមួយនិងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិកឬ ក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេលើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹម ត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 និងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពចលនាសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវៈ

( ក ) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់ពីនោះធ្វើការអនុវត្តន៍ឱ្យបានជាប់លាប់ ។

( ខ ) អនុលោមទៅតាមស្តង់គណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវគឺត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

( គ ) រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព ។

( ឃ ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែ មានករណីមិនសមរម្យក្នុងការសន្មត់ថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត ដែលគិតទុកជាមុន ។

( ង ) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាពលើរាល់សេចក្តីសំរេច ដែលមានសារៈសំខាន់ ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការ ហើយត្រូវធ្វើឱ្យប្រាកដថាកិច្ចការ នេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលៈ

Talmage Mark Payne
*ប្រធានក្រុមប្រឹក្សាភិបាល*
3 0 MAR 2012

លឹម ហាក់ឃុន
*នាយកប្រតិបត្តិ*
3 0 MAR 2012



# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះម្ចាស់ភាគហ៊ុនហ្វឹស ហ្វាយនែន ភីអិលស៊ី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្វឹស ហ្វាយនែន ភីអិលស៊ី ហៅ កាត់ថា (□ក្រុមហ៊ុន□) ដែលរួមមានតារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 និងរបាយការណ៍លទ្ធផល របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន និងរបាយការណ៍ចលនាសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សំគាល់ដែលរួមមានសេចក្តីសង្ខេបលើគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗដែលបានបង្ហាញនៅទំព័រទី 8 ដល់ទី 44 ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយ ការណ៍ហិរញ្ញវត្ថុនេះដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីកំហុសឆ្គងជាសារវន្តដោយសារតែការក្លែងបន្លំ ឬការភាន់ច្រឡំ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្ម អន្តរជាតិនៃកម្ពុជា ។ ស្តង់ដារទាំងនេះតម្រូវឱ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ ដោយគ្រោង និងធ្វើសវនកម្មដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំមាន កំហុសឆ្គងជាសារវន្តឡើយ ។

ការធ្វើសវនកម្ម រួមមានការអនុវត្តន៍នូវបណ្តានិតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់ និងកំណត់បង្ហាញទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនិតិវិធីទាំងនេះ គឺផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យដែលមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាទៅលើការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ពន្ធ័ទៅនឹងការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដើម្បីធ្វើសវនកម្មឱ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់ទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។ ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានសំខាន់ៗដែលធ្វើឡើងដោយគណៈគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## មតិយោបល់

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាព ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពចលនាសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការ កំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

**តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់**

Craig McDonald
*Audit Partner*

រាជធានីភ្នំពេញ

ថ្ងៃទី 30 ខែ មីនា ឆ្នាំ 2012

# តារាងតុល្យការ
## នៅថ្ងៃទី 31 ខែ ធ្នូ 2011

| | 2011<br>ដុល្លារអាមេរិក | 2011<br>ពាន់រៀល 000<br>( កំណត់សំគាល់ 4 ) | 2010<br>ដុល្លារអាមេរិក |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ក្នុងដៃ | 819 | 3,308 | 730 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | 268,329 | 1,083,781 | 209,546 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 114,469 | 462,340 | 15,000 |
| ឥណទានផ្តល់ដល់អតិថិជន | 3,299,857 | 13,328,122 | 2,049,039 |
| គណនីត្រូវទទួលផ្សេងៗ | 59,832 | 241,661 | 23,292 |
| ទ្រព្យ និងបរិក្ខា | 53,717 | 216,963 | 21,903 |
| សរុបទ្រព្យសកម្ម | 3,797,023 | 15,336,175 | 2,319,510 |
| **បំណុល និងមូលនិធិម្ចាស់ហ៊ុន** | | | |
| **បំណុល** | | | |
| គណនីត្រូវទូទាត់ផ្សេងៗ | 49,287 | 199,069 | 11,472 |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវទូទាត់ | 27,863 | 112,539 | 4,315 |
| ប្រាក់កម្ចី | 1,300,000 | 5,250,700 | 1,989,370 |
| សរុបបំណុល | 1,377,150 | 5,562,308 | 2,005,157 |
| **មូលនិធិម្ចាស់ហ៊ុន** | | | |
| ដើមទុន | 2,289,370 | 9,246,765 | 300,000 |
| ប្រាក់ចំណេញរក្សាទុក | 130,503 | 527,102 | 14,353 |
| សរុបមូលនិធិម្ចាស់ហ៊ុន | 2,419,873 | 9,773,867 | 314,353 |
| សរុបបំណុល និងមូលនិធិម្ចាស់ហ៊ុន | 3,797,023 | 15,336,175 | 2,319,510 |

# របាយការណ៍លទ្ធផល
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

| | 2011<br>ដុល្លារអាមេរិក | 2011<br>ពាន់រៀល 000<br>( កំណត់សំគាល់ 4 ) | 2010<br>ដុល្លារអាមេរិក |
|---|---|---|---|
| ចំណូលពីការប្រាក់ | 466,365 | 1,883,648 | 214,656 |
| ចំណាយលើការប្រាក់ | ( 54,161 ) | ( 218,756 ) | - |
| ចំណូលសុទ្ធពីការប្រាក់ | 412,204 | 1,664,892 | 214,656 |
| ចំណូលប្រតិបត្តិការផ្សេងៗ | 71,849 | 290,198 | 51,660 |
| ចំណូលប្រតិបត្តិការ | 484,053 | 1,955,090 | 266,316 |
| សំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ | ( 33,332 ) | ( 134,628 ) | - |
| ចំណាយប្រតិបត្តិការ និងចំណាយផ្សេងៗ | ( 302,495 ) | ( 1,221,777 ) | ( 202,472 ) |
| ប្រាក់ចំណេញមុនដកពន្ធ | 148,226 | 598,685 | 63,844 |
| ពន្ធលើប្រាក់ចំណេញ | ( 32,076 ) | ( 129,555 ) | ( 6,482 ) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ ការិយបរិច្ឆេទ | 116,150 | 469,130 | 57,362 |

# របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 1

| | ដើមទុន<br>ដុល្លារអាមេរិក | ( ប្រាក់ខាតបង្គរ )/<br>ប្រាក់ចំណេញរក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2010 | 300,000 | ( 43,009 ) | 256,991 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | 57,362 | 57,362 |
| សមតុល្យនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ | 300,000 | 14,353 | 314,353 |
| ផ្ទេរពីប្រាក់កម្ចីទៅជាដើមទុន | 1,989,370 | - | 1,989,370 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | 116,150 | 116,150 |
| សមតុល្យនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ | 2,289,370 | 130,503 | 2,419,873 |
| សមមូលជាពាន់រៀល | 9,246,765 | 527,102 | 9,773,867 |

# របាយការណ៍ចលនាសាច់ប្រាក់

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 1

| | | 2011 | 2010 |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល 000<br>( កំណត់សំគាល់ 4 ) | ដុល្លារអាមេរិក |
| **ចលនាសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការសាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង**<br>សកម្មភាពប្រតិបត្តិការ | ( 1,201,935 ) | ( 4,854,615 ) | ( 1,510,437 ) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ**<br>ការទិញទ្រព្យ និងបរិក្ខា | ( 39,193 ) | ( 158,301 ) | ( 24,048 ) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | ( 39,193 ) | ( 158,301 ) | ( 24,048 ) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន**<br>ប្រាក់ទទួលបានពីប្រាក់កម្ចី | 1,450,000 | 5,856,550 | 1,489,370 |
| ការទូទាត់សងប្រាក់កម្ចី | ( 150,000 ) | ( 605,850 ) | - |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | 1,300,000 | 5,250,700 | 1,489,370 |
| ការកើនឡើង/( ថយចុះ )នៃសាច់ប្រាក់<br>និងសាច់ប្រាក់សមមូល | 58,872 | 237,784 | ( 45,115 ) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល<br>នាដើមការិយបរិច្ឆេទ | 210,276 | 849,305 | 255,391 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល<br>នាចុងការិយបរិច្ឆេទ | 269,148 | 1,087,089 | 210,276 |
| ក្នុងការិយបរិច្ឆេទមានប្រតិបត្តិការមិនចំណាយសាច់ប្រាក់ចំបងដូចខាងក្រោម:<br>ការផ្ទេរពីប្រាក់កម្ចីទៅជាដើមទុន | 1,989,370 | 8,035,065 | - |



# យើងត្រៀមជាស្រេចសំរាប់
# កំណើនអាជីវកម្ម
# តំណាក់កាលបន្ទាប់

FIRST FINANCE

A HOME WITHIN REACH

អាគារ A-15-17 ផ្លូវលេខ 271 សង្កាត់ ទំនប់ទឹក
ខណ្ឌ ចំការមន ភ្នំពេញ រាជាណាចក្រកម្ពុជា
T: +855 (0) 023 997 937 | F: +855 (0) 23 997 937
E: info@firstfinance.biz | W: www.firstfinance.biz
www.facebook.com/firstfinance